# អំពី IBAC

www.ibac.vic.gov.au

Khmer

អ្នកមានសិទ្ធិដើម្បីរំពឹងទុកថានិយោជិតវិស័យសាធារណៈ និងមន្ត្រីប៉ូលីសបំពេញកិច្ចការដែលផ្តល់នូវឧត្តមប្រយោជន៍ដល់អ្នក ដោយពុំទទួលរងឥទ្ធិពលពីផលប្រយោជន៍ផ្ទាល់ខ្លួន ភាពលោភលន់ ឬគោលបំណងឧក្រិដ្ឋ។ ដើម្បីជួយរក្សាទំនុកចិត្តរបស់អ្នកនៅក្នុងវិស័យសាធារណៈ IBAC ធ្វើការដើម្បីបង្ការ ហើយបើកបង្ហាញអំពើពុករលួយ ឬការប្រព្រឹត្តមិនត្រឹមត្រូវដែលធ្វើឲ្យខូចខាតប្រាក់សាធារណៈ និងបំផ្លាញអាយុជីវិត។

## IBAC គឺជាភ្នាក់ងារប្រឆាំងអំពើពុករលួយរបស់រដ្ឋវិចតូរីយ៉ា

ទស្សនៈរបស់ IBAC គឺសម្រាប់វិស័យសាធារណៈដែលប្រឆាំងតទល់យ៉ាងសកម្មទៅនឹងអំពើពុករលួយ។

យើងធ្វើការដើម្បីឈានឆ្ពោះទៅដល់ចំណុចនេះដោយ៖

1. ទទួលយកការប្ដឹងរាយការណ៍ និងការជូនដំណឹងអំពីអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវនៃវិស័យសាធារណៈ (រួមមានការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីស និងការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងការិយាល័យសាធារណៈ)
2. ស៊ើបអង្កេត និងបើកបង្ហាញអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវដោយកំណត់អាទិភាពទៅលើបញ្ហាធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធ
3. ជូនដំណឹងដល់វិស័យសាធារណៈ ប៉ូលីស និសហគមន៍អំពីហានិភ័យ និងផលប៉ះពាល់នៃអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹម ហើយនិងវិធីទាំងឡាយដែលវាអាចបង្ការកុំឲ្យកើតមាន។

## 1. ការរាយការណ៍អំពីអំពើពុករលួយ

រៀងរាល់ឆ្នាំ IBAC ទទួលបានការចោទប្រកាន់ប្រហែល៥០០០ករណី ទាក់ទងនឹងអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវក្នុងវិស័យសាធារណៈ។ ព័ត៌មាននេះមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធ្វើការបើកបង្ហាញអំពើពុករលួយ ហើយកំណត់អត្តសញ្ញាណទំនោរ និងហានិភ័យដែលកំពុងលេចឡើងនៅទូទាំងវិស័យសាធារណៈផងដែរ។

IBAC ធ្វើការវាយតម្លៃលើការប្ដឹងរាយការណ៍នីមួយៗដោយប្រុងប្រយ័ត្ន ពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាន ជាមួយនឹងការស្រាវជ្រាវរបស់យើង និងការប្ដឹងរាយការណ៍ដទៃទៀត និងការកាន់កាប់ព័ត៌មាន ស៊ើបការណ៍សម្ងាត់។ បន្ទាប់មកយើងសម្រេចចិត្តថាតើត្រូវ៖

- **បញ្ជូនបន្តការប្ដឹងរាយការណ៍**ទៅកាន់ភ្នាក់ងារមួយផ្សេងទៀត ដូចជាមន្ត្រីស៊ើប អង្កេតការប្ដឹងរាយការណ៍ពលរដ្ឋវិចតូរីយ៉ា (Victorian Ombudsman), ប៉ូលីសរដ្ឋវិចតូរីយ៉ា (Victoria Police) ឬភ្នាក់ងារអំពីការប្ដឹងរាយការណ៍នោះ។ IBAC ជារឿយៗ ធ្វើការត្រួតពិនិត្យឡើងវិញនូវលទ្ធផលនៃបញ្ហាទាំងនេះ ដើម្បីធានាថាបញ្ហា ទាំងនោះត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវ។
- **ស៊ើបអង្កេតការប្ដឹងរាយការណ៍**ដោយខ្លួនយើងផ្ទាល់។ IBAC អាចធ្វើការសាកសួរក្នុងជំហានដំបូង ដើម្បីជួយជូនដំណឹងពីការសម្រេចចិត្តនេះ។
- **មិនចាត់វិធានការតទៅទៀត។**

## អំណាចច្បាប់របស់ IBAC - វិស័យសាធារណៈរដ្ឋវិចតូរីយ៉ា



### រដ្ឋាភិបាលរដ្ឋ

- ក្រសួង
- ភ្នាក់ងារ/ការិយាល័យ
- សេវាកម្មថែទាំសុខភាពសាធារណៈ
- សាលារៀន
- វិទ្យាស្ថាន TAFEs និងសាកលវិទ្យាល័យ



### សាលាសង្កាត់

- ទីប្រឹក្សាសាលាសង្កាត់
- បុគ្គលិកសាលាសង្កាត់



### ប៉ូលីសរដ្ឋវិចតូរីយ៉ា (Victoria Police)

- មន្ត្រីប៉ូលីសមានអំណាចអនុវត្តច្បាប់
- មន្ត្រីផ្នែកសេវាកម្មការពារ (PSOs)
- មន្ត្រីជ្រើសរើសប៉ូលីស
- មន្ត្រីប៉ូលីសផ្នែកឃុំឃាំង
- និយោជិត



### សភា

- MPs
- មន្ត្រីចាត់ចែងការបោះឆ្នោត
- បុគ្គលិកថ្នាក់ក្រសួង



### អង្គចៅក្រម

ចៅក្រម
ចៅក្រមតុលាការជាន់ទាប
និងសមាជិកនៃអង្គភាពតុលាការដទៃទៀត រួមមាន៖

- តុលាការកំពូល
- តុលាការប្រចាំខេត្តដី
- តុលាការស៊ើបអង្កេតការស្លាប់
- តុលាការជាន់ទាប
- VCAT

ibac independent broad-based anti-corruption commission
Victoria

### តើអំពើពុករលួយវិស័យសាធារណៈជាអ្វី?

អំពើពុករលួយអាចជានិយោជិតវិស័យសាធារណៈប្រព្រឹត្តការគែបន្លំ ទទួល ឬផ្តល់សំណូក សម្រេចផ្តល់ការចុះកិច្ចសន្យាទៅឲ្យក្រុមគ្រួសារ ឬមិត្តភ័ក្តិ និងការប្រើប្រាស់ ឬធ្វើឲ្យលេចធ្លាយនូវព័ត៌មានប្រកបដោយអភ័យឯកសិទ្ធិសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។

### តើការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងការិយាល័យសាធារណៈជាអ្វី?

ការប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងការិយាល័យសាធារណៈ អាចជាការប្រព្រឹត្តណាមួយដោយនិយោជិត វិស័យសាធារណៈដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ ឬខកខានមិនបានបំពេញតាមបទដ្ឋានសីលធម៌ ឬវិជ្ជាជីវៈដែលតម្រូវឲ្យមាននៅក្នុងការបំពេញតួនាទី ឬការប្រើប្រាស់អំណាចដែលបានប្រគល់ជូនដល់ពួកគេ។

### តើការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីសជាអ្វី?

IBAC ក៏ទទួលយកការប្តឹងរាយការណ៍ផងដែរ អំពីការប្រព្រឹត្តមិនត្រឹមត្រូវដោយបុគ្គលិកប៉ូលីសរដ្ឋវិចតូរីយ៉ា (Victoria Police) ទាំងអស់ រួមមានមន្ត្រីប៉ូលីសមានអំណាចអនុវត្តច្បាប់ មន្ត្រីជ្រើសរើសបុគ្គលិក និយោជិត និង PSOs។

ការប្រព្រឹត្តមិនត្រឹមត្រូវ អាចជាបុគ្គលិកប៉ូលីសចែកចាយសម្ភារៈដែលមានលក្ខណៈប្រមាថមើលងាយ ការបើកបរទាំងស្រវឹង ការធ្វើកំណត់ត្រាខុសនៅក្នុងបញ្ជីកំណត់ត្រា/បញ្ជីចុះកំណត់ហេតុ ឬការប្រើប្រាស់កម្លាំងជ្រុលហួសហេតុ។

## 2. ការស៊ើបអង្កេតអំពើពុករលួយ

តាមច្បាប់ IBAC ត្រូវតែកំណត់អាទិភាពការចោទប្រកាន់អំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងរ ឬជាលក្ខណៈប្រព័ន្ធនៅក្នុងវិស័យសាធារណៈ។ IBAC អាចជ្រើសរើសធ្វើការស៊ើបអង្កេតលើការប្តឹងរាយការណ៍ ឬការជូនដំណឹង ឬយើងអាចចាប់ផ្តើមការស៊ើបអង្កេតដោយ "សកម្មភាពផ្ទាល់ខ្លួនរបស់យើង"។ ការស៊ើបអង្កេតរបស់យើងកំណត់ថាតើអំពើពុករលួយ ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលិកប៉ូលីស បានកើតមានឡើងឬអត់។ ការរៀបចំបទចោទប្រកាន់ឧក្រិដ្ឋកម្ម ឬណែនាំផ្តល់ជាអនុសាសន៍នូវចំណាត់ការបន្ថែមតទៅទៀត ទាំងនេះគឺគ្រាន់តែជាលទ្ធផលដែលអាចមានមួយចំនួនប៉ុណ្ណោះ។ យើងក៏អាចចេញផ្សាយរបាយការណ៍ផងដែរ ហើយផ្តល់អនុសាសន៍ណែនាំដើម្បីកែលម្អឲ្យប្រសើរឡើងទៅលើប្រព័ន្ធ ឬការអនុវត្តន៍។

### ធ្វើការចាត់ចែងត្រួតពិនិត្យ

ការត្រួតពិនិត្យគឺជាផ្នែកមួយនៃដំណើរការស៊ើបអង្កេតរបស់ IBAC ហើយជាទូទៅត្រូវបានរក្សាជាលក្ខណៈឯកជន។ ស្នងការរបស់យើងអាចចាត់ចែងសវនាការជាសាធារណៈ ប្រសិនបើស្នងការចាត់ទុកថា៖

- មានកាលៈទេសៈយ៉ាងពិសេស
- វាជាផលប្រយោជន៍សាធារណៈ
- សវនាការទាំងនេះអាចធ្វើឡើង ដោយមិនបង្កការខូចខាតដោយគ្មានហេតុផលត្រឹមត្រូវទៅដល់កេរ្តិ៍ឈ្មោះ សុវត្ថិភាព ឬសុខុមាលភាពរបស់ជនណាម្នាក់។

### ការប្រើប្រាស់អំណាចរបស់ IBAC ដោយមានការទទួលខុសត្រូវ

ក្នុងអំឡុងពេលនៃការស៊ើបអង្កេត IBAC អាច៖

- ទាមទារឲ្យបានជាដាច់ខាតនូវការបង្កើតឯកសារ និងវត្ថុផ្សេងដទៃទៀត
- ចូល និងឆែកឆេរបរិវេណ រឹបអូសយកឯកសារ និងរបស់របរ
- ប្រើប្រាស់ឧបករណ៍តាមដានឃ្លាំមើល ស្ទាក់ចាប់ការផ្តោះប្តូរព័ត៌មានទូរគមនាគមន៍
- ធ្វើការត្រួតពិនិត្យជាឯកជន និងជាសាធារណៈ
- តម្រូវឲ្យមនុស្សផ្តល់ភស្តុតាងនៅកន្លែងសវនាការ។

យើងត្រូវតែដាក់ពាក្យសុំទៅកាន់តុលាការ និងសាលាក្តី មុនពេលប្រើប្រាស់អំណាចខ្លះនៃអំណាចទាំងនេះ។ យើងក៏ធ្វើសេចក្តីរាយការណ៍យ៉ាងទៀងទាត់ផងដែរទៅកាន់បណ្តារដ្ឋនានា និងអង្គការរដ្ឋស្តីពីការប្រើប្រាស់អំណាចរបស់យើង។

## 3. ការបង្ការអំពើពុករលួយ

យើងទាំងអស់គ្នាមានការទទួលខុសត្រូវ ដើម្បីបង្ការអំពើពុករលួយនៅក្នុងវិស័យសាធារណៈ និងដើម្បីធានាឲ្យបានថា មូលនិធិសាធារណៈកំពុងត្រូវបានចំណាយស្របទៅតាមគោលបំណង - ការផ្តល់ជូននូវសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលសំខាន់ៗសម្រាប់ពលរដ្ឋវិចតូរីយ៉ាគ្រប់រូប។

ការបង្ការអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងរនៅក្នុងវិស័យសាធារណៈគឺជាអាទិភាពសំខាន់សម្រាប់ IBAC ជាអាទិភាពមួយដែលអង្គការទាំងមូលចូលរួមចំណែកវិភាគទាន។

រួមគ្នាជាមួយនឹងដៃគូរសំខាន់ៗរបស់យើង នៅទូទាំងប្រព័ន្ធសុច្ចរិតភាពរបស់រដ្ឋ IBAC បានតាក់តែងរៀបចំ ផ្តល់ជូន និងវាយតម្លៃលើអន្តរាគមន៍បង្ការនានាគ្រប់ជ្រុងជ្រោយដើម្បី៖

- ផ្តល់អំណាចដល់បុគ្គលដើម្បីកំណត់អត្តសញ្ញាណ និងរាយការណ៍ពីអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងរ
- ជួយគាំទ្រដល់អង្គការទាំងឡាយ ដើម្បីបង្កើតនូវការត្រួតពិនិត្យអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព
- ពង្រឹងបទដ្ឋានសង្គម ដើម្បីបង្កើតឲ្យមានវប្បធម៌ប្រឆាំងនឹងអំពើពុករលួយដ៏រឹងមាំ ហើយមានស្ថេរភាពយូរអង្វែង។

### ការយល់ដឹងពីផលប៉ះពាល់នៃអំពើពុករលួយ

ដើម្បីយល់ដឹងឲ្យកាន់តែប្រសើរឡើង នូវវិស័យដែលងាយរងគ្រោះបំផុតទៅនឹងការដែលត្រូវបានកេងប្រវ័ញ្ច ឬពុករលួយ យើងទទួលអនុវត្តការស្រាវជ្រាវយុទ្ធសាស្ត្រទៅក្នុងទំនោរ និងបញ្ហា ហើយនិងគម្រោងសំខាន់ៗដទៃទៀត ដែលបានបង្ហាញឲ្យឃើញច្បាស់នូវឱកាសសម្រាប់ការកែលម្អឲ្យកាន់តែប្រសើរឡើងនៅក្នុងប្រព័ន្ធ និងការអនុវត្តន៍។ ក្នុងខណៈដែលវាអាចជួយជូនដំណឹងដល់ការស៊ើបអង្កេតរបស់យើង ការស្រាវជ្រាវនេះក៏ត្រូវបានប្រើប្រាស់ផងដែរដើម្បី៖

- ធ្វើឲ្យពាក់ព័ន្ធជាមួយសហគមន៍ និងវិស័យសាធារណៈ ដើម្បីកែលម្អឲ្យកាន់តែប្រសើរឡើងនូវការយល់ដឹងពីអំពើពុករលួយ និងទុក្ខទោសគ្រោះថ្នាក់របស់វា
- កែលម្អឲ្យកាន់តែប្រសើរឡើងនូវការរាយការណ៍ពីអំពើពុករលួយ ហើយជួយកសាងសមត្ថភាពវិស័យសាធារណៈ ដើម្បីបកស្រាយពីរបាយការណ៍
- ផ្តល់ជូនការប្រុងប្រយ័ត្នដល់ដល់អង្គការនានា ទៅនឹងព័ត៌មាន និងការស៊ើបយកការណ៍ថ្មីៗចុងក្រោយបំផុត ដើម្បីឲ្យដឹងជាមុនអំពីហានិភ័យនៃអំពើពុករលួយ។

Level 1 North Tower
459 Collins Street
Melbourne VIC 3000
GPO Box 24234
Melbourne VIC 3001

ទូរស័ព្ទ 1300 735 135
ទូរសារ (03) 8635 6444

ខែមករា ឆ្នាំ 2017

IBAC គឺជាភ្នាក់ងារប្រឆាំងអំពើពុករលួយរបស់រដ្ឋវិចតូរីយ៉ា ដែលទទួលខុសត្រូវក្នុងការបង្ការ និងបើកបង្ហាញអំពើពុករលួយនៅក្នុងវិស័យសាធារណៈ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីស។ យើងបំពេញកិច្ចការនេះដោយ៖

- ស៊ើបអង្កេតអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវធ្ងន់ធ្ងររបស់ប៉ូលីស
- ជូនដំណឹងដល់វិស័យសាធារណៈ ប៉ូលីស និសហគមន៍អំពីហានិភ័យ និងផលប៉ះពាល់នៃអំពើពុករលួយ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់ប៉ូលីស ហើយនិងវិធីទាំងឡាយដែលវាអាចបង្ការកុំឲ្យកើតមាន។

ដើម្បីស្វែងយល់អំពីរបៀបរាយការណ៍ពីអំពើពុករលួយ សូមចូលទៅកាន់វិបសាយ **www.ibac.vic.gov.au** ឬ ទូរស័ព្ទលេខ **1300 735 135** ។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែភាសា សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយលេខ **13 14 50** ឬចូលទៅកាន់វិបសាយ **www.ibac.vic.gov.au/general/accessibility/tr**

*សន្លឹកឯកសារនេះគឺសម្រាប់ជាគោលបំណងព័ត៌មានតែប៉ុណ្ណោះ ហើយមិនគួរចាត់ទុកថាជាព័ត៌មានជំនួសឱវាទផ្លូវច្បាប់ឡើយ។*